**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុ
# កិច្ចប្រជុំលើកទី៣របស់ក្រុមការងាររេដ+កម្ពុជា

ឆ្នាំពីរពាន់ដប់បួន ខែកុម្ភៈ ថ្ងៃទីម្ភៃមួយ វេលាម៉ោងពីរនិងសាមសិបនាទី នៅសណ្ឋាគារ៉ាហ្វល់ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញមានបើកកិច្ចប្រជុំលើកទី៣ក្រុមការងាររេដបូកកម្ពុជាក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ និងជាប្រធានក្រុមការងាររេដបូកកម្ពុជា។

កិច្ចប្រជុំនេះរៀបចំឡើងដោយលេខាធិការដ្ឋានរេដបូក ដោយមានអ្នកចូលរួមសរុបចំនួន២១នាក់ រួមមាន៖ សមាជិកក្រុមការងាររេដបូក ០៤នាក់ តំណាងជំនួសសមាជិកក្រុមការងាររេដបូក ០៣នាក់ អ្នករៀបចំមកពីលេខាធិការដ្ឋានរេដ+១០នាក់ និងមន្ត្រីមកពីអង្គការដៃគូគាំទ្រកម្មវិធីរេដបូកសំខាន់ៗ ចំនួន០៤នាក់។ (ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០១៖ បញ្ជីឈ្មោះអ្នកចូលរួម)

## មតិចាប់ផ្តើមបើកអង្គប្រជុំ

ឯកឧត្តមបណ្ឌិត ជា សំអាង ជាប្រធានអង្គប្រជុំបានចាប់ផ្តើមបើកកិច្ចប្រជុំស្វាគមន៍សមាជិក និងតំណាងជំនួសសមាជិកក្រុមការងាររេដបូកកម្ពុជាដែលបានចូលរួមកិច្ចប្រជុំ និងស្នើសុំពិនិត្យនិងអនុម័តលើរបៀបវារៈនៃកិច្ចប្រជុំលើកទី៣នេះ។

(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០២៖ របៀបវារៈកិច្ចប្រជុំលើកទី៣ក្រុមការងាររេដបូក)

## បទបង្ហាញ និងកិច្ចពិភាក្សា

### ១-វឌ្ឍនភាពនៃការសម្រេចរបស់កិច្ចប្រជុំលើកទី២

លោកអ៊ុយ កាម៉ាល បានជម្រាបជូនអង្គប្រជុំថា៖ ដោយអនុវត្តតាមការសម្រេចរបស់កិច្ចប្រជុំលើកទី២ លេខាធិការដ្ឋានបានរៀបចំការងារដូចខាងក្រោម៖

- បានអញ្ជើញមន្ត្រីបច្ចេកទេសដែលបានចាត់បញ្ជូនពីស្ថាប័នពាក់ព័ន្ធមកចូលរួមកិច្ចប្រជុំស្តីពីយន្តការថវិការេដបូកនិងកិច្ចប្រជុំលើកទី១ក្រុមបច្ចេកទេស។ មន្ត្រីបច្ចេកទេសដែលបានចាត់បញ្ជូនទាំងអស់បានចូលរួម លើកលែងមន្ត្រីអគ្គនាយកដ្ឋានថាមពលដែលអវត្តមាន ដោយសារមានបញ្ហាបែបបទរដ្ឋបាលនៅពេលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានចែកជាពីរ។
- ស្ថាប័នពាក់ព័ន្ធបានចាត់បញ្ជូនមន្ត្រីមកចូលរួមក្រុមបច្ចេកទេសលើកលែងក្រសួងអភិវឌ្ឍជនបទ។ លិខិតចាត់បញ្ជូនមន្ត្រីក៏បានថតចម្លងចែកជូនអ្នកពាក់ព័ន្ធ និងបានរៀបចំជាបញ្ជីឈ្មោះក្រុមបច្ចេកទេស និងអាស័យដ្ឋានទំនាក់ទំនងផងដែរ។
- បានកែសម្រួលយុទ្ធសាស្ត្រទំនាក់ទំនងរេដបូក និងបានថតចម្លងសេចក្តីសំរេច UNFCCC ចាប់ពី COP15 ដល់ COP19 ចែកជូនក្រុមការងាររេដបូក ដូចមានឯកសារភ្ជាប់ជូន។

- បានរៀបចំទស្សនៈកិច្ចសិក្សានៅវៀតណាមជូនក្រុមការងាររេដបូកដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៣ ដល់១៧ ខែមករា ឆ្នាំ២០១៤។

(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០៣៖ បទបង្ហាញពីវឌ្ឍនភាពនៃការសម្រេចក្នុងកិច្ចប្រជុំលើកទី២)

## ការពិភាក្សា

លោក ដោក ដូម៉ា៖ ស្នើសុំលេខាធិការដ្ឋានធ្វើលិខិតស្នើសុំមន្ត្រីចូលរួមក្នុងក្រុមការងារបច្ចេកទេសសារជាថ្មី ដោយដាក់ជូនទៅអគ្គនាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុនៃក្រសួងអភិវឌ្ឍជនបទ។

ឯកឧត្តមបណ្ឌិត ជា សំអាង បានស្នើសុំឲ្យលោក លន់ គឹមហ៊ី រាយការណ៍ពីវឌ្ឍនភាពការងាររបស់ក្រុមបច្ចេកទេសទាំងបួនបន្ទាប់ពីកិច្ចប្រជុំលើកទី១។

លោក លន់ គឹមហ៊ីបានជម្រាបអង្គប្រជុំថា៖ ក្រុមបច្ចេកទេសរេដទាំង៤បានរៀបចំផែនការសកម្មភាពនៅក្នុងកិច្ចប្រជុំក្រុមបច្ចេកទេសលើកទី១នៅខេត្តព្រះសីហនុលើកលែងតែក្រុម MRV ដែលមិនទាន់បានធ្វើ។ ក្នុងចំណោមក្រុមបច្ចេកទេសទាំងអស់ ក្រុមបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពឈានមុខជាងគេព្រោះថាក្រុមនេះបានបញ្ចប់របាយការណ៍ពិនិត្យមើល និងវិភាគគោលនយោបាយ ច្បាប់និងបទបញ្ញត្តិដែលមានស្រាប់ដែលជាឯកសារសំខាន់សម្រាប់គាំទ្រដល់ការរៀបចំប្រព័ន្ធធានាសុវត្ថិភាព។

លោក អ៊ុយ កាម៉ាល៖ បន្ទាប់ពីកិច្ចប្រជុំនៅខេត្តព្រះសីហនុ ក្រុម MRV បានប្រជុំចំនួន២លើក និងបានពិនិត្យពិភាក្សាលើផែនការបន្ត។

លោក ដោក ដូម៉ា៖ ស្នើសុំឲ្យបកប្រែកូនសៀវភៅស្តីពីសេចក្តីសម្រេចរបស់សន្និសីទនៃបណ្តាប្រទេសជាភាគី (COP) ជាភាសាខ្មែរ។

កញ្ញា ធី ហៀង៖ បញ្ជាក់ថាកូនសៀវភៅនេះនឹងបន្តកែសម្រួលដោយរួមបញ្ចូលសេចក្តីសម្រេចនៃសន្និសិទ នៅទីក្រុងBali, Cancun និង Durban និងសង្ខេបសេចក្តីសម្រេចនីមួយៗ។ ប្រសិនបើអាចធ្វើបានលេខាធិការដ្ឋាននឹងបកប្រែជាភាសាខ្មែរ។

## ការសម្រេច

- លោក លន់ គឹមហ៊ី នឹងរៀបចំលិខិតជាថ្មីជូនទៅអគ្គនាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ នៃក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីសុំចាត់មន្ត្រីមកចូលរួមក្នុងក្រុមបច្ចេកទេសរេដបូក។
- កញ្ញា ធី ហៀង នឹងកែសម្រួលកូនសៀវភៅស្តីពីសេចក្តីសម្រេចរបស់សន្និសីទនៃបណ្តាប្រទេសជាភាគីនិងពិចារណាពីការបកប្រែជាភាសាខ្មែរ។

## ២. បច្ចុប្បន្នភាពកម្មវិធីរេដបូកនៅកម្ពុជា

លោក ឈុន ឌីលុច បានធ្វើបទបង្ហាញដែលផ្តោតសំខាន់លើ៖

- ស្ថានភាពរេដ+កម្ពុជាធៀបនឹងប្រទេសនានា
- សមាសភាគទី១៖ ការគ្រប់គ្រង ទំនាក់ទំនង និងជម្រុញអ្នកពាក់ព័ន្ធចូលរួមអនុវត្តន៍
- សមាសភាគទី២៖ សមាសធាតុបច្ចេកទេសសម្រាប់យុទ្ធសាស្ត្ររេដ+ជាតិ
- សមាសភាគទី៣៖ ការកសាងសមត្ថភាពថ្នាក់ក្រោមជាតិ និងការអនុវត្តគម្រោងគំរូ

ភ្ជាប់ពីគេហទំព័រមួយទៅគេហទំព័រមួយទៀតជាការប្រសើរ ព្រោះស្ថាប័ននីមួយៗគេមានគេហទំព័ររបស់ខ្លួន ម្យ៉ាងទៀតរដ្ឋបាលថ្នាក់ក្រោមជាតិក៏មានគេហទំព័រផងដែរ។

កញ្ញា ធី ហៀង៖ បានថ្លែងអរគុណចំពោះការផ្តល់យោបល់ អនុសាសន៍ និងការជួយគាំទ្រ និងសន្យាទទួលយកយោបល់ទាំងអស់ទៅអនុវត្តតាមដែលអាចធ្វើបាន។ បច្ចុប្បន្នលេខាធិការដ្ឋានកំពុងបន្តផលិតវីដេអូអប់រំខ្លីៗចំនួន០៤ និងខិតប័ណ្ណផ្សព្វផ្សាយចំនួន០៤អំពីរេដបូក ដោយផ្តោតលើផ្នែក MRV, ការបែងចែកផលប្រយោជន៍, សហប្រយោជន៍ក្រោមការអនុវត្តរេដបូក, ប្រព័ន្ធធានាសុវត្ថិភាព, និងមូលហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើ។ យើងមានផែនការផ្សព្វផ្សាយឲ្យបានទូលាយ នៅពេលដែលសម្ភារៈអប់រំផ្សព្វផ្សាយបានផលិត និងបោះពុម្ព។ ការផ្សព្វផ្សាយនោះរួមមាន៖ ការចាក់វីដេអូអប់រំ នៅតាមខេត្ត ដែលអនុវត្តន៍រេដ+ និងការផលិតដើម្បីផ្សព្វផ្សាយតាមកម្មវិធីទូរទស្សន៍ និងវិទ្យុឲ្យកាន់តែទូលំទូលាយ។ គេហទំព័រយើងបានភ្ជាប់ជាមួយនឹងស្ថាប័នពាក់ព័ន្ធមួយចំនួនធំ និងបន្តធ្វើទៅតាមការស្នើ និងការផ្តល់ មតិ។

ឯកឧត្តមបណ្ឌិត ជា សំអាង៖ គាំទ្រការបង្កើនការផ្សព្វផ្សាយឲ្យកាន់តែទូលំទូលាយ និងការបកប្រែរៀបចំគេហទំព័រជាភាសាខ្មែរ។ ពេលខាងមុខការងារនឹងមានការកើនឡើង ដូច្នេះយើងនឹងជ្រើសរើសជំនួយការ ផ្នែកទំនាក់ទំនង ដើម្បីជួយការងារនេះ។ ប្រសិនបើមានតម្រូវការយល់ដឹងអំពីរេដបូកឬសម្ភារៈព័ត៌មានផ្សព្វផ្សាយ អំពីរេដបូកឬ វគ្គបណ្តុះបណ្តាលអំពីរេដបូកក្រសួងពាក់ព័ន្ធ សូមស្នើសុំមកលេខាធិការដ្ឋាន។

**ការសម្រេច**

- ការសិក្សាលើកក្រោយត្រូវធ្វើឲ្យបានច្បាស់លាស់ ជាពិសេសវិធីសាស្ត្រ និងសំណាក និងសុំឲ្យមានការបង្ហាញនូវវិធីសាស្ត្រ ប្រសិនបើមានការសិក្សាលើកក្រោយ។
- កញ្ញា ធី ហៀង នឹងទំនាក់ទំនងជាមួយមន្ត្រីនៅក្រសួងមហាផ្ទៃ ពាក់ព័ន្ធនិងការផ្សព្វផ្សាយ និងការទំនាក់ទំនង ជាពិសេសទៅលើការផ្សព្វផ្សាយតាមសហគមន៍ ឬ/និង ថ្នាក់ក្រោមជាតិ។

## ៣- ប្រធានបទពិភាក្សា

### ៣.១. ការពិចារណាលើការអនុវត្តរេដ+ នៅថ្នាក់ជាតិ ឬ ក្រោមជាតិ ឬ គម្រោង

បទបង្ហាញបានធ្វើឡើងដោយ លោក ភីធ័រ អ៊ីវ៉ីសិន ដោយផ្តោតសំខាន់លើ៖

- រេដ+ផ្អែកតាមគម្រោង (Project)
- រេដ+ថ្នាក់ក្រោមជាតិ(Subnational)
- រេដ+ថ្នាក់ជាតិ(National)
- លទ្ធភាពនៃការទទួលបានថវិកាលើកទឹកចិត្តរេដ+
- ភាពស្មុគស្មាញ និងវិបាកនៃជម្រើសនីមួយៗ

(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០៥៖ បទបង្ហាញស្តីពីជម្រើសពផ្សេងគ្នានៃការអនុវត្តរេដបូក)

**ការពិភាក្សា**

- សមាសភាគទី៤៖ ប្រព័ន្ធត្រួតពិនិត្យថ្នាក់ជាតិ

(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០៤៖ បទបង្ហាញស្តីពីបច្ចុប្បន្នភាពកម្មវិធីរេដបូកនៅកម្ពុជា)

## ការពិភាក្សា

លោក ដោក ដូម៉ា៖ ពាក់ព័ន្ធនឹងស្ថានភាពរេដបូកនៅកម្ពុជាធៀបនឹងប្រទេសនានាសុំឲ្យធ្វើការបកស្រាយបញ្ជាក់ទៅលើចំនុច "ទស្សនៈរបស់អ្នកពាក់ព័ន្ធ"។

លោក អ៊ុក វិបុលៈ "ការយល់ដឹងរបស់អ្នកពាក់ព័ន្ធនៅកម្ពុជាលើការងារវិស័យមានកម្រិតខ្ពស់ ប៉ុន្តែបើធៀបទៅនឹងចំនុចចុងក្រោយនៃបទបង្ហាញ គឺកម្ពុជាយើងមានកម្រិតខ្សោយលើបច្ចេកទេស ដូច្នេះសុំធ្វើការបកស្រាយបញ្ជាក់លើចំនុចនេះ។

លោក ភីធី៖ បញ្ជាក់ថាលទ្ធផលនៃការសិក្សាបានមកពីថ្នាក់តំបន់ ដែលការសិក្សាបានធ្វើតាមរយៈ Onlineលើក្រុមគោលដៅដែលពាក់ព័ន្ធនឹងរេដបូកជាពិសេសមន្ត្រីរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ។ ការសិក្សានេះធ្វើឡើងនៅប្រទេសមួយចំនួននៅអាស៊ីដែលអនុវត្តកម្មវិធីរេដបូក។

លោក ស៊ិន ស៊ុនសុភក្តិ (តំណាង ឯ. ជាម ប៉េអា) បានផ្តល់មតិថា៖ ការងារប្រព័ន្ធធានាសុវត្ថិភាពឈានមុខជាងគេជាការប្រសើរ ប៉ុន្តែលោកសុំឲ្យមានការយកចិត្តទុកដាក់លើយុទ្ធសាស្ត្រអនុវត្តទាំងមូល ព្រោះថាដំណើរការល្អតែការងារប្រព័ន្ធធានាសុវត្ថិភាពតែមួយមិនគ្រប់គ្រាន់ទេ។

លោក ដោក ដូម៉ា៖ ការសិក្សាសុំឲ្យបានគ្រប់ជ្រុងជ្រោយ ជាពិសេសសំណាក និងវិធីសាស្ត្រ នៃការប្រមូលទិន្នន័យ។ តាមរយៈ Online ជាវិធីសាស្ត្រដែលអាចប្រើបានចំពោះអ្នកដែលមានកម្រិតយល់ដឹងខ្ពស់ ដូច្នេះមិនអាចតំណាងគ្រប់អ្នកពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជាបានទេ។ ម្យ៉ាងទៀតមិនសូវមានអ្នកបំពេញ ឬឆ្លើយតបនឹងកម្រងសំណួរដែលបានផ្ញើឡើយ។ ដូច្នេះលទ្ធផលនៃការសិក្សានេះមិនអាចប្រើប្រាស់បានទូលំទូលាយ និងគ្មានប្រសិទ្ធិភាពទេ។ ដូច្នេះគួរមានការសិក្សា និងប្រៀបធៀបឲ្យបានល្អជាងនេះ។

ឯកឧត្តមបណ្ឌិត ជា សំអាង៖ សន្និដ្ឋានថាលទ្ធផលមិនមានភាពរឹងមាំ និងពិបាកក្នុងការយកមកប្រើប្រាស់ ដោយសារប្រភពអ្នកឆ្លើយតបមិនគ្រប់គ្រាន់ និងវិធីសាស្ត្រមិនច្បាស់លាស់។ ការសិក្សាលើកក្រោយ គឺសុំឲ្យមានវិធីសាស្ត្រ ការជ្រើសរើសសំណាក និងវិភាគឲ្យច្បាស់លាស់ជាងនេះ និងជាពិសេសនៅពេលបង្ហាញសុំឲ្យដាក់ប្រភពនិងព័ត៌មានឲ្យបានលម្អិតជាងនេះ។

លោក ស៊ិន ស៊ុនសុភក្តិ៖ សុំកោតសសើរការរៀបចំគេហទំព័ររេដបូកកម្ពុជា ព្រោះលោកអាចរកបានឯកសារជាច្រើនពីគេហទំព័រនេះ ប៉ុន្តែគួរមានគេហទំព័រជាភាសាខ្មែរ ដើម្បីឲ្យការផ្សព្វផ្សាយអំពីរេដបូកកាន់តែទូលំទូលាយជាងនេះ និងត្រូវមានសម្ភារៈព័ត៌មានផ្សេងៗបន្ថែមទៀត សម្រាប់ផ្សព្វផ្សាយទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិនិងសហគមន៍។ ក្រសួងមហាផ្ទៃបានធ្វើការជាច្រើនជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍ ដូច្នេះប្រសិនបើចង់ដឹងពីបទពិសោធន៍និងវិធីសាស្ត្រដែលក្រសួងមហាផ្ទៃបានធ្វើសុំទាក់ទង ទៅមន្ត្រីផ្នែកទំនាក់ទំនង និងបច្ចេកវិទ្យានៃក្រសួងមហាផ្ទៃ។ ការចែកចាយព័ត៌មានតាមរយៈបច្ចេកវិទ្យាជាការល្អដោយសារប្រជាពលរដ្ឋយើងសព្វថ្ងៃកំពុងព្យាយាម ប្រើប្រាស់ប្រព័ន្ធនេះ ពីព្រោះវាអាចចែករំលែកព័ត៌មានបានឆាប់រហ័សជាងការចែកចាយតាមរយៈឯកសារថតចម្លង។ ដូច្នេះប្រសិនបើមានការ

លោក ដោក ដូម៉ា៖ រដ្ឋបាលព្រៃឈើ ទើបអាចដឹងថាកម្រិតនីមួយៗនៃរេដបូកមានការលំបាកប៉ុណ្ណា ប៉ុន្តែបើពិនិត្យទៅលើស្ថានភាពប្រទេសយើង កម្រិតគម្រោងមានភាពមិនយូរអង្វែង ជាពិសេសពេលគម្រោង ឬ ជំនួយបញ្ចប់ គម្រោងភាគច្រើនត្រូវបានបញ្ចប់ដែរ។ លោកសង្កេតឃើញថានៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានច្បាប់ និងមានគោលការណ៍វិមជ្ឈការ និងសហវិមជ្ឈការ (Decentralization and Deconcentration) ដែលក្រសួងមហាផ្ទៃកំពុងអនុវត្ត។ ដូច្នេះរេដបូកនៅថ្នាក់ក្រោមជាតិជាជម្រើសដែលគួរពិចារណា។

លោក ស៊ន ស៊ុនសុភក្តិ៖ ជម្រើសនេះស្ថាប័នសំខាន់ៗដូចជារដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ក្រសួងបរិស្ថាន គួរសិក្សានិងពិនិត្យទៅលើបទពិសោធន៍ដែលធ្លាប់បានអនុវត្តកន្លងមកមុននឹងសម្រេច។

ឯកឧត្តមបណ្ឌិត ជា សំអាង៖ ការងារនេះមានភាពស្មុគស្មាញច្រើន។ លោក ភីធី បានបង្ហាញថារេដបូក នៅថ្នាក់គម្រោងមានភាពស្មុគស្មាញជាងកម្រិតថ្នាក់ជាតិ គឺត្រូវចំណាយថវិកាច្រើន មានស្តង់ដាការងារខុសៗគ្នា និងការទទួលខុសត្រូវក៏មានកម្រិត។ ម្យ៉ាងវិញទៀត សមាជិកអង្គប្រជុំបានលើកឡើងពីជម្រើសនៅថ្នាក់ក្រោមជាតិថាមានយន្តការ និងរចនាសម្ព័ន្ធមានស្រាប់ដែលមានការចូលរួម និងការទទួលខុសត្រូវ។ ទោះជាយ៉ាងណាក៏ដោយ ការងារព្រៃឈើ និងរេដបូកជាការទទួលខុសត្រូវខ្ពស់ណាស់និងត្រូវធានាថា ព្រៃឈើមិនបាត់បង់ ដូច្នេះជាការចាំបាច់ត្រូវមានការចូលរួមទាំងអស់គ្នា។ ប្រសិនបើខ្វះការចូលរួមពីថ្នាក់ក្រោមជាតិ ការគ្រប់គ្រងនឹងខ្វះស្ថេរភាព ដូច្នេះការអនុវត្តមិនអាចទទួលជោគជ័យបានឡើយ។ ចំណុចសំខាន់មួយទៀត ការចែករំលែកផលប្រយោជន៍ ដល់អ្នកអនុវត្តត្រូវធានាឲ្យចំគោលដៅទើបការចូលរួមមានស្ថេរភាព។ បច្ចុប្បន្ននេះយើងកំពុងស្ថិតនៅក្នុងដំណាក់កាលត្រៀមលក្ខណៈរេដបូក ដូច្នេះយើងត្រូវសិក្សានិងពិនិត្យរាល់បទពិសោធន៍ និងមតិយោបល់ ដើម្បីដាក់ជូនទៅថ្នាក់ដឹកនាំដើម្បីធ្វើការសម្រេច។

លោក ស៊ន ស៊ុនសុភក្តិ៖ បានផ្តល់ព័ត៌មានថាសិក្ខាកាមដែលចូលរួមកិច្ចប្រជុំលើកកម្ពស់ការយល់ដឹងអំពីរេដបូក មានកង្វល់ថាប្រសិនបើមានការអនុវត្តគម្រោងរេដបូកថ្នាក់ក្រោមជាតិពួកគាត់មិនដឹងថាត្រូវអនុវត្តដោយរបៀបណាឲ្យត្រូវតាមស្តង់ដាអន្តរជាតិ និងជាពិសេសមិនដឹងថាត្រូវចែករំលែកផលប្រយោជន៍ដោយរបៀបណា ដូច្នេះសមាជិកក្រុមការងាររេដបូកត្រូវគិតគូរឲ្យបានល្អិតល្អន់មុនពេលសម្រេចចិត្តថាអនុវត្តគម្រោងក្នុងកម្រិតណាមួយ។

**ការសម្រេច**

- ជម្រើសនៃការអនុវត្តរេដបូកនៅ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់គម្រោង ត្រូវការពេលវេលាបន្ថែមទៀត ដើម្បីសិក្សានិងពិភាក្សានៅតាមក្រុមគោលដៅ និងក្រុមការងារ ដូច្នេះមិនអាចសម្រេចនៅពេលនេះបានទេ។

## ៣.២. ផែនការពហុឆ្នាំសម្រាប់រេដបូកនៅកម្ពុជា

បទបង្ហាញបានធ្វើឡើងដោយ កញ្ញា ណាអូមី ដោយផ្តោតទៅលើ៖

- Outcome 1: ប្រសិទ្ធិភាពនៃការគ្រប់គ្រងថ្នាក់ជាតិលើដំណើរការត្រៀមលក្ខណៈរេដបូក និងការចូលរួមរបស់អ្នកពាក់ព័ន្ធ

- Outcome 3:ពង្រឹងសមត្ថភាពគ្រប់គ្រងរេដបូកនៅថ្នាក់ក្រោមជាតិ
- Outcome 4:បង្កើតប្រព័ន្ធត្រួតពិនិត្យ និងក្របខណ្ឌកំរិតយោងមួយ និងសមត្ថភាពអនុវត្ត

(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០៦៖ បទបង្ហាញស្តីពីសេចក្តីព្រាងផែនការសកម្មភាពពហុឆ្នាំ)

## ការពិភាក្សា

លោក ស៊ិន ស៊ុនសុភក្តិ៖ សូមសរសើចំពោះការរៀបចំផែនការពហុឆ្នាំ ប៉ុន្តែលោកមានសំនួរទាក់ទងនឹងលទ្ធផល 2.4 និងសំណូមពរកំណត់ឲ្យបានជាក់លាក់ ជាពិសេសសុំឲ្យមានលម្អិតសកម្មភាព និងសូចនាករ ដើម្បីបញ្ជាក់ថាតើឆ្លើយតបនឹងលទ្ធផលដែរឬទេ?

លោក សៅ រ៉ាវី៖ ផែនការពហុឆ្នាំនេះរៀបចំបានល្អ ប៉ុន្តែដើម្បីឲ្យកាន់តែប្រសើរជាងនេះទៀត យើងគួរកំណត់អាទិភាពប្រភេទ ឬកម្រិតដែលត្រូវអនុវត្ត។

លោក ភីតធី៖ ផែនការសកម្មភាពជាឯកសាររស់ មានន័យថាយើងអាចកែសម្រួល និងផ្លាស់ប្តូរអាស្រ័យទៅតាមតម្រូវការចាំបាច់។

លោក អ៊ុក វិបុល៖ Outcome 3 ពង្រឹងសមត្ថភាពគ្រប់គ្រងរេដបូកនៅថ្នាក់ក្រោមជាតិ ប៉ុន្តែសកម្មភាពទំនងជាមិនឆ្លើយតបនឹងOutcome ដូច្នេះគួរតែមានសកម្មភាពកសាងសមត្ថភាព។

លោក អ៊ុយ កាម៉ាល៖ ផែនការពហុឆ្នាំនេះ មិនបានរំលេចសកម្មភាពដែលអាចយកទៅអនុវត្តបានទេ ប្រហែលជាយើងត្រូវរៀបចំឲ្យចេញជាផែនការសកម្មភាពមួយទៀត។ ម្យ៉ាងវិញទៀតផែនការពហុឆ្នាំនេះ មានគម្រោងចំនួនបី (UNREDD, CAMREDD និង FCPF) គាំទ្រការអនុវត្ត។ ដូច្នេះត្រូវមានការបញ្ជាក់ច្បាស់ថាសកម្មភាពនីមួយគាំទ្រដោយគម្រោងណា ឬគាំទ្ររួមគ្នា។

លោក អ៊ុកវិបុល៖ ក្រុមការងាររេដបូកគួរពិនិត្យត្រឹមផែនការមេ (ផែនការពហុឆ្នាំ) ប៉ុន្តែមិនបាច់ពិនិត្យដល់សកម្មភាពលម្អិតទេ គួរពិនិត្យត្រឹមសកម្មភាពសំខាន់ៗឆ្លើយតបនឹង Outcome ប្រសើជាង។

លោក លន់ គឹមហ៊ី៖ ផែនការពហុឆ្នាំមានភាពទូលំទូលាយ និងមិនបញ្ជាក់ពីសកម្មភាពលម្អិតតូចៗនោះទេ ប៉ុន្តែអ្វីដែលសំខាន់ កញ្ញា ណាអូមី ចង់បង្ហាញឲ្យឃើញថា CAM-REDD ក៏មានសកម្មភាពខ្លះឆ្លើយតបទៅនឹងក្របខណ្ឌលទ្ធផលនៃការត្រៀមលក្ខណៈសម្រាប់រេដ+នៅកម្ពុជាផងដែរ។ ប្រសិនបើយើងមានបំណងពិនិត្យផែនការសកម្មភាពលម្អិតនោះ គឺមានផែនការសកម្មភាពនិងថវិកា ប្រចាំឆ្នាំរបស់ UNREDD ឬ CAM-REDD។

លោក អ៊ុក វិបុល៖ ប្រសិនបើសកម្មភាពទាំងអស់នេះ ចម្លងចេញពីឯកសារសំណៅដើម លោកគិតថាមិនចាំបាច់ពិភាក្សានោះទេ ប៉ុន្តែកញ្ញា ណាអូមី បានបង្ហាញថានាងជាអ្នករៀបចំផែនការពហុឆ្នាំ។

កញ្ញា ណាអូមី៖ យល់ស្របតាមសំណូមពរ ឲ្យមានសកម្មភាព និងសូចនាករឆ្លើយតបនឹងលទ្ធផល។ ទាក់ទងនឹងចំណុច 3.1 និង3.2 គឺបានចម្លងពីឯកសារ ប៉ុន្តែដើម្បីឲ្យសមាជិកងាយស្រួលយល់កញ្ញានឹងកែសម្រួលតាមយោបល់។

ឯកឧត្តមបណ្ឌិត ជា សំអាង៖ ចំណុច 3.1 នឹងកែទៅជា"ពង្រឹងសមត្ថភាពអនុវត្តសកម្មភាពគម្រោងសាកល្បង"។

លោក ស៊ិន ស៊ុនសុភក្តិ៖ ផែនការនេះមានរយៈពេលវែង បើដាក់តែសកម្មភាពរួមធំៗដូច្នេះនឹងមាន ការលំបាកក្នុងការតាមដាននិងអនុវត្ត ដូច្នេះយើងគួរពិនិត្យឡើងវិញ និងរៀបចំផែនការនេះឲ្យបាន ច្បាស់លាស់ ដោយបន្ថែមឲ្យមានអ្នកទទួលខុសត្រូវ និងពេលវេលា។

**ការសម្រេច**

- កញ្ញា ណាអូមី នឹងរៀបចំឡើងវិញផែនការពហុឆ្នាំ ដើម្បីបង្ហាញជូនក្រុមការងាររេដបូក។
- កិច្ចប្រជុំលើកក្រោយសុំឲ្យមានការបង្ហាញផែនការសកម្មភាពឆ្នាំ២០១៨ដោយមានសកម្មភាពលម្អិត ដើម្បីបង្ហាញជូនក្រុមការងាររេដបូក។

## ៣.៣. យេនឌ័រ និង រេដបូក

លោក លន់ គឹមហ៊ី បានធ្វើបទបង្ហាញពីលទ្ធផលនៃការសិក្សាស្តីពីយេនឌ័រពាក់ព័ន្ធនិងរេដបូកនៅកម្ពុជាដែលផ្តោតលើ៖ ១)ចំណុចល្អៗពីការអនុវត្ត ២)ឧបសគ្គផ្សេងៗនៅកម្រិតគោលនយោបាយ និងស្ថាប័នកម្រិតសហគមន៍ ៣)ចំណុចល្អជួយដោះស្រាយឧបសគ្គ ៤)ចំណុចអាចជួយអន្តរាគមន៍។ ចុងបញ្ចប់នៃបទបង្ហាញ លោក លន់ គឹមហ៊ី បានស្នើសុំការឲ្យបង្កើតក្រុមយេនឌ័រ ដើម្បីជួយផ្តល់យោបល់លើឯកសាររេដបូកដែលបានព្រាងរៀបចំ។

(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធ០៧៖ បទបង្ហាញស្តីពីយេនឌ័រ និង រេដបូក)

**ការពិភាក្សា**

លោក ស៊ិន ស៊ុនសុភក្តិ៖ បានជូនយោបល់ថាកន្លងមក លោកសង្កេតឃើញមានបណ្តាញនិងគណកម្មការយេនឌ័រជាច្រើនបានបង្កើតនៅតាមស្ថាប័ននានា ដូច្នេះយើងគួរពិចារណាប្រើប្រាស់បណ្តាញ ឬ គណកម្មការដែលមានស្រាប់ជាជាងការបង្កើតថ្មី។ ក្រសួងកិច្ចការនារី បានបង្កើតឲ្យមានបណ្តាញយេនឌ័រជាពិសេសនៅថ្នាក់ក្រោមជាតិមានគណកម្មការពិគ្រោះយោបល់ស្ត្រី និងកុមារ ដែលដឹកនាំដោយសមាជិកក្រុមប្រឹក្សាខេត្តមួយរូបជាស្ត្រីនិងមានសមាជិកមកពីមន្ទីរនិងអង្គភាពជុំវិញខេត្ត។

លោក អ៊ុក វិបុល ជូនយោបល់ថា៖ បណ្តាញយេនឌ័រដែលបង្កើតដោយក្រសួងកិច្ចការនារីជាបណ្តាញកម្រិតជាតិផ្តោតលើបញ្ហាយេនឌ័រជាទូទៅ។ ដោយឡែកនៅតាមស្ថាប័ន អង្គភាព និង ថ្នាក់រដ្ឋបាលនីមួយៗ មានគណកម្មការយេនឌ័រដែលបានបង្កើតឡើងដោយផ្តោតសំខាន់លើបញ្ហាបច្ចេកទេស និងជំនាញជាក់លាក់។ គណកម្មការយេនឌ័រនៅតាមស្ថាប័នអង្គភាព និងថ្នាក់រដ្ឋបាលទាំងនេះ នឹងរាយការណ៍ជូនបណ្តាញយេនឌ័រជាតិដែលបង្កើតដោយក្រសួងកិច្ចការនារីពីបញ្ហានិងវឌ្ឍនភាពការងារយេនឌ័ររបស់ខ្លួនដូច្នេះយើងអាចបង្កើតក្រុមយេនឌ័ររេដបូកបាន។ ដូច្នេះសមាជិកក្រុមការងាររេដបូកយើង គួរសម្របសម្រួលបញ្ជូនតំណាងយេនឌ័រមកចូលរួមក្នុងក្រុមយេនឌ័ររេដបូកនេះ ដើម្បីឲ្យពួកគាត់អាចផ្តល់យោបល់លើបញ្ហារេដបូកនិងចែករំលែកព័ត៌មានត្រលប់ទៅបណ្តាញធំរបស់ពួកគាត់វិញ។ ការបង្កើតក្រុមយេនឌ័ររេដបូកមិនត្រូវធំពេកទេ ដែលនាំឲ្យមានការលំបាកក្នុងការសម្របសម្រួល។ ក្រុមយេនឌ័ររេដបូកគួរមានកម្រិតស្មើនឹងក្រុមការងារបច្ចេកទេសរេដបូក។

លោក ស៊ិន ស៊ិនសុភក្តិ៖ ប្រសិនបើយើងចង់បង្កើតក្រុមយេនឌ័រតែក្នុងបរិបទរេដបូក លោកគាំទ្រយោបល់លោកអ៊ុកវិបុលប៉ុន្តែប្រសិនបើចង់បង្កើតនៅកម្រិតជាតិ ឬក្រោមជាតិ លោករក្សាគំនិតដដែល។

ឯកឧត្តមបណ្ឌិត ជា សំអាង៖ កញ្ញា ធី ហៀង ត្រូវធ្វើការសិក្សាលើយន្តការ ឬបណ្តាញដែលមានស្រាប់មុននឹងធ្វើសេចក្តីព្រាងបង្កើតក្រុមយេនឌ័ររេដបូកនេះដើម្បីជៀសវាងការបង្កើតក្រុមជាន់គ្នានាំឲ្យគ្មានប្រសិទ្ធភាព។

លោក អ៊ុយ កាម៉ាល៖ បានរំលឹកពីតួនាទីរបស់ក្រុមប្រឹក្សាយោបល់ និងស្នើយោបល់ថា តើយើងអាចបន្ថែមតួនាទីយេនឌ័រមួយទៀតឲ្យក្រុមប្រឹក្សាយោបល់នេះបានដែរឬទេ? ប្រសិនបើមិនអាចចាំយើងបង្កើតថ្មី។

លោក ស៊ិន ស៊ិនសុភក្តិ៖ ការបង្កើតក្រុមយេនឌ័ររេដបូកជាបញ្ហាមួយ ប៉ុន្តែការបង្កើតក្រុមនេះឲ្យមានប្រសិទ្ធភាពគឺជាបញ្ហាសំខាន់បំផុត។ ដូច្នេះនៅពេលបង្កើត គួរកំណត់នូវភាគរយស្ត្រី សិទ្ធក្នុងការធ្វើសេចក្តីសម្រេច និងកំណត់ថាតើគម្រោងឆ្លើយតបនឹងតម្រូវការរបស់ស្ត្រីបានកម្រិតណា?

ឯកឧត្តមបណ្ឌិត ជា សំអាង៖ បានថ្លែងអំណរគុណចំពោះសមាជិកដែលបានចូលរួមមតិយោបល់ និងយល់ស្រប ចំពោះការគិតគូរពិចារណាជាពិសេសទៅលើតម្រូវការ និងការសម្រេចចិត្តរបស់ស្ត្រី។

**ការសម្រេច**

- កញ្ញា ធី ហៀង នឹងលោកស្រី ម៉ូអ៊ីកូ ត្រូវសិក្សានិងធ្វើសេចក្តីព្រាងបង្កើតក្រុមយេនឌ័ររេដបូកនេះ។

## ៣.៤. បញ្ហាផ្សេងៗ

**ការពិភាក្សា**

លោក អ៊ុក វិបុល៖ លេខាធិការដ្ឋានត្រូវសម្របសម្រួលកំណត់ថ្ងៃប្រជុំកុំឲ្យជាន់គ្នា និងសុំជំរះថវិកាចុះបេសកម្ម (ទូទាត់សង) ឲ្យបានឆាប់រហ័ស។

ឯកឧត្តមបណ្ឌិត ជា សំអាង៖ លេខាធិការដ្ឋាន ពិនិត្យនិងកែលំអបញ្ហានេះ។ ឯកឧត្តម ស្នើសុំតំណាងពីក្រុមការងាររេដបូកចូលរួមជាសមាជិកគណកម្មការអនុម័តលើសំណើគម្រោងសហគមន៍ព្រៃឈើអនុវត្តរេដបូក។

លោក អ៊ុយ កាម៉ាល៖ សមាជិកគណកម្មការនេះគួរជ្រើសយកសមាជិកក្រុមការងាររេដបូកមកពីអង្គភាពស្ថាប័នជំនាញពាក់ព័ន្ធសំខាន់ៗ។

លោក អ៊ុក វិបុល៖ ការចូលរួមនេះគួរផ្លាស់ប្តូរវេនគ្នារវាងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និងក្រសួងបរិស្ថាន ពីព្រោះស្ថាប័នទាំងបីនេះមានភាពពាក់ព័ន្ធជាងគេ។

ឯកឧត្តមបណ្ឌិត ជា សំអាង៖ ទទួលយកយោបល់ និងសុំឲ្យលោក អ៊ុក វិបុល ជាតំណាងចូលរួម។

ឯកឧត្តមបណ្ឌិត ជា សំអាង៖ ស្នើសុំពិចារណាផ្តល់ការឧបត្ថម្ភថវិកាចំណាយលើការទំនាក់ទំនង (កាតទូរស័ព្ទ) ដល់ក្រុមបច្ចេកទេសរេដបូកទាំងបួនក្រុម។ តើការផ្តល់ថវិកាឧបត្ថម្ភ ចំណាយលើការទំនាក់ទំនង នេះអាចមានបញ្ហាពាក់ព័ន្ធនិងថវិកា ឬ ហិរញ្ញវត្ថុដែរឬទេ?

លោកស្រី ប៉ាន់ ធីតា៖ ក្រុមការងាររេដបូក ជាអ្នកអនុម័តលើបញ្ហានេះ ខ្ញុំ(ធីតា) គ្រាន់តែជាអ្នកអនុវត្តតាមការសម្រេចប៉ុណ្ណោះ។ សមាជិកក្រុមការងាររេដបូក បានទទួលការឧបត្ថម្ភថវិកាចំណាយលើការ

ទំនាក់ទំនង មិនលើស ពី៥០ដុល្លារក្នុង១ខែ ដូច្នេះក្រុមបច្ចេកទេសរេដបូកត្រូវតែតិចជាងនេះ ច្រើនបំផុត ត្រឹម៤០ដុល្លារក្នុងមួយខែ។

**ការសម្រេច**

- លោក អ៊ុក វិបុល ត្រូវបានចាត់តាំងជាតំណាងចូលរួមក្នុងកិច្ចប្រជុំសមាជិកគណកម្មការអនុម័ត លើសំណើគម្រោងសហគមន៍ព្រៃឈើអនុវត្តរេដបូកលើកទី១។
- កិច្ចប្រជុំបានសម្រេចផ្តល់ការឧបត្ថម្ភថវិកាចំណាយលើការទំនាក់ទំនងសម្រាប់ក្រុមបច្ចេកទេស រេដបូកច្រើនបំផុតត្រឹម៤០ដុល្លារក្នុងមួយខែ។

## ៤- មតិបូកសរុបពីអង្គប្រជុំ

ឯកឧត្តមបណ្ឌិត ជា សំអាងប្រធានអង្គប្រជុំ បានបូកសរុបការសម្រេចសំខាន់ៗក្នុងកិច្ចប្រជុំរួមមាន៖

- សុំឲ្យរៀបចំកូនសៀវភៅស្តីពីសេចក្តីសម្រេចរបស់COP ឡើងវិញឲ្យបានត្រឹមត្រូវងាយយល់ និង បកប្រែជាភាសាខ្មែរ ប្រសិនជាអាចធ្វើទៅបាន។
- ចំពោះការសិក្សាវាយតម្លៃ សុំឲ្យមានវិធីសាស្ត្រ ក្រុមគោលដៅ និងបង្ហាញលទ្ធផលឲ្យបានល្អជាង នេះជាពិសេសសូមដាក់ប្រភពនៃការសិក្សា។ ប្រសិនបើមានការសិក្សាពេលក្រោយ សុំឲ្យមានការ បង្ហាញជាមុន ជៀសវាងទទួលបានលទ្ធផលដែលមិនអាចប្រើប្រាស់បាន។
- ការបង្ហាញពីកម្រិតផ្សេងៗនៃការអនុវត្តគម្រោងរេដបូក បានធ្វើឲ្យសមាជិកក្រុមការងាររេដបូកយល់ដឹង ស្តីពីការអនុវត្តរេដបូកកាន់តែប្រសើរឡើង។
- ចំពោះផែនការពហុឆ្នាំសុំឲ្យមានការកែសម្រួលទៅតាមអនុសាសន៍និងយោបល់ដែលបានផ្តល់ឲ្យ។
- កញ្ញា ធី ហៀង នឹងលោកស្រី ម៉ូអ៊ីកូ ត្រូវសិក្សា និងធ្វើសេចក្តីព្រាងបង្កើតក្រុមយេនឌ័ររេដបូកនេះ។
- សុំឲ្យមានតារាងកំណត់ពី សកម្មភាពការងារ កាលបរិច្ឆេទ ពេលវេលា ដើម្បីជៀសវាងកុំឲ្យជាន់ គ្នាជាមួយដៃគូអនុវត្តន៍ផ្សេងៗច្រើនពេក។ ម្យ៉ាងទៀតការអញ្ជើញអ្នកចូលរួមសុំកុំឲ្យជាន់គ្នាដែរ។
- ការឧបត្ថម្ភចំណាយទំនាក់ទំនងក្រុមបច្ចេកទេសរេដបូកច្រើនបំផុតត្រឹម៤០ដុល្លារក្នុងមួយខែ។

ចុងបញ្ចប់ ឯកឧត្តមបណ្ឌិតប្រធានអង្គប្រជុំ បានថ្លែងអំណរគុណចំពោះអ្នកចូលរួមទាំងអស់ដែល បានចូលរួមមតិយោបល់និងអនុសាសន៍។ ជាមួយគ្នានេះដែរ សុំឲ្យលេខាធិការដ្ឋានយកចិត្តទុកដាក់បន្ថែម ទៀតលើការគ្រប់គ្រង សម្របសម្រួលការងារឲ្យកាន់តែមានប្រសិទ្ធភាព និងមានគុណភាពប្រសើរឡើង។

កិច្ចប្រជុំលើកទី៤ នឹងធ្វើឡើងនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤។

**អ្នកធ្វើកំណត់ហេតុ**

**ប្រធានអង្គប្រជុំ**

បានឃើញ និង ឯកភាព

កញ្ញា ធី ហៀង

មន្ត្រីទំនាក់ទំនងលេខាធិការដ្ឋានរេដ+កម្ពុជា

# បញ្ជីវត្តមាន

# កិច្ចប្រជុំលើកទី៣ក្រុមការងារ REDD+ កម្ពុជា

| ក្រុមការងាររេដបូកកម្ពុជា | | | |
|---|---|---|---|
| ១ | ឯកឧត្តម ជា សំអាង | ប្រធានក្រុមការងាររេដបូកកម្ពុជា | វត្តមាន |
| ២ | លោក អ៊ុក វិបុល | សមាជិកក្រុមការងាររេដបូកកម្ពុជា | វត្តមាន |
| ៣ | លោក សៅ វ៉ារី | សមាជិកក្រុមការងាររេដបូកកម្ពុជា | វត្តមាន |
| ៤ | លោកបណ្ឌិត ដោក ដូម៉ា | សមាជិកក្រុមការងាររេដបូកកម្ពុជា | វត្តមាន |
| ៥ | លោក អ៊ុយ កាម៉ាល | សមាជិកជំនួស លោក គឹម ណុង | វត្តមាន |
| ៦ | លោក ស៊ិន ស៊ុនសុភក្តិ | សមាជិកជំនួស ឯកឧត្តម ជាម ប៉េអា | វត្តមាន |
| ៧ | កញ្ញា សាង សុគន្ធី | សមាជិកជំនួសលោកជំទាវ ពៅ វលក្ខណ៍ | វត្តមាន |
| ៨ | ឯកឧត្តម នេត មុន្នី | សមាជិកក្រុមការងាររេដបូកកម្ពុជា | អវត្តមាន |
| ៩ | លោកបណ្ឌិត កែវ អូម៉ាលីស្ស | សមាជិកក្រុមការងាររេដបូកកម្ពុជា | អវត្តមាន |
| ១០ | លោក សំ ខាន់ឌី | សមាជិកក្រុមការងាររេដបូកកម្ពុជា | អវត្តមាន |

| លេខាធិការដ្ឋាន និងដៃគូគាំទ្រ | | | |
|---|---|---|---|
| ១ | លោក លន់ គឹមហ៊ី | អ្នកសម្របសម្រួលកម្មវិធី | សម្របសម្រួលកិច្ចប្រជុំ |
| ២ | លោក ឈុន ឌីលុច | មន្ត្រីបច្ចេកទេសលេខាធិការដ្ឋាន | ធ្វើបទបង្ហាញ |
| ៣ | លោក ភីធ័រ អ៊ីវើស៊ិន | អ្នកឯកទេសរេដបូកគាំទ្របច្ចេកទេស | ធ្វើបទបង្ហាញ |
| ៤ | កញ្ញា ណាអ៊ូមី ម៉ាតស៊ុយ | អ្នកឯកទេស CAM-REDD | ធ្វើបទបង្ហាញ |
| ៥ | កញ្ញា ធី ហៀង | មន្ត្រីទំនាក់ទំនង | កត់ត្រា-ធ្វើរបាយការណ៍ |
| ៦ | លោក ងួន ភក្តី | បេក្ខបណ្ឌិតហាត់ការ | បកប្រែ-ជួយកត់ត្រា |
| ៧ | លោកស្រី ប៉ាន់ ធីតា | មន្ត្រីហិរញ្ញវត្ថុ និងលទ្ធកម្ម | ចាត់តាំងកម្មវិធី -ភស្តុភារ |
| ៨ | លោក តេង ហួត | ជំនួយការរដ្ឋបាល-ហិរញ្ញវត្ថុ | រៀបចំភស្តុភារ-សម្ភារៈ |
| ៩ | លោកស្រី ឌុក សេរីវឌ្ឍនា | ជំនួយការរដ្ឋបាល | រៀបចំភស្តុភារ-សម្ភារៈ |
| ១០ | លោកស្រី ម៉ូអ៊ីកូ សៃតូ ជិនស៊ីន | អ្នកវិភាគកម្មវិធីអង្គការ UNDP | ដៃគូគាំទ្រកម្មវិធី |
| ១១ | លោក អ៊ីរ៉ូស៊ី ណាកាតា | ទីប្រឹក្សា DG-FA | ដៃគូគាំទ្រកម្មវិធី |

**ក្រុមការងារកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការបាត់បង់ និងរេចរឹលព្រៃឈើប្រទេសកម្ពុជា**

# កិច្ចប្រជុំលើកទី៣ក្រុមការងាររេដ+កម្ពុជា

***ទីកន្លែងប្រជុំ:*** *សណ្ឋាគារ៉ាហ្វល់ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ*

***កាលបរិច្ឆេទ:*** *ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤ (២:៣០- ៥:១៥នាទី រសៀល)*

## របៀបវារៈកិច្ចប្រជុំ

| | | |
|---|---|---|
| ២:០០-២:៣០ | - ចុះឈ្មោះអ្នកចូលរួម | - មន្ត្រីលេខាធិការដ្ឋាន |
| ២:៣០-២:៤០ | <u>បើកអង្គប្រជុំ</u><br>- មតិចាប់ផ្តើមបើកអង្គប្រជុំ | <br>- ប្រធានអង្គប្រជុំ |
| ២:៤០-២:៥០ | <u>វឌ្ឍនភាពនៃការសម្រេចក្នុងកិច្ចប្រជុំលើកទី២</u> | - លោកអ៊ុយកាម៉ាល |
| ២:៥០-៣:៣០ | <u>បច្ចុប្បន្នភាពកម្មវិធីរេដ+នៅកម្ពុជា</u><br>- ស្ថានភាពរេដ+កម្ពុជាធៀបនឹងប្រទេសនានា<br>- សមាសភាគទី១<br>- សមាសភាគទី២<br>- សមាសភាគទី៣<br>- សមាសភាគទី៤ | - លោកឈុនឌីលុច |
| ៣:៣០-៤:៥០ | <u>ប្រធានបទពិភាក្សា</u><br>- ការពិចារណាលើការអនុវត្តរេដ+នៅថ្នាក់ជាតិឬក្រោមជាតិឬគម្រោង<br>- ផែនការពហុឆ្នាំសម្រាប់រេដ+នៅកម្ពុជា<br>- យែនឌ័រនិងរេដ+<br>- បញ្ហាផ្សេងៗ | <br>- លោកគីជ័រអ៊ីវីសិន<br>- កញ្ញា ណាអូមី<br>- លោកលន់គឹមហុី |
| ៤:៥០-៥:០០ | <u>បិទអង្គប្រជុំ</u><br>- មតិបូកសរុបនិងបិទអង្គប្រជុំ<br>- ការថតរូបជាក្រុម | <br>- ប្រធានអង្គប្រជុំ |
| ៥:០០-៥:៣០ | - សម្រាកអាហារសម្រន់ | |

ក្រុមការងារការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការបាត់បង់ និងរេចរឹលព្រៃឈើប្រទេសកម្ពុជា

## The Third Meeting of the REDD+ Taskforce

Place: Raffle Hotel le Royal Phnom Penh
Date: 21 February 2014 (02:30 - 05:15 pm)

Agenda

| | | |
|---|---|---|
| 02:00 - 02:30 | Registration | RTS staff |
| 02:30 - 02:40 | Open session<br>❖ Opening Remark | Chair of meeting |
| 02:40 - 02:50 | ❖ Progress against decision in the 2nd Taskforce meeting | Mr. Khun Vathana |
| 02:50 - 03:30 | Update REDD+ programme<br>❖ Where Does Cambodia Stand?<br>❖ Component 1<br>❖ Component 2<br>❖ Component 3<br>❖ Component 4 | Mr. Chhun Delux |
| 03:30 - 04:50 | Topics for Discussion:<br>❖ REDD+ Options<br>❖ Multiple years workplan<br>❖ Gender and REDD+<br>❖ Other issues | <br>Mr. Peter Iversen<br>Ms. Naomi<br>Mr. Lun Kimhy |
| 04:50 – 05:00 | Closed session<br>❖ Closing Remark | Chair of meeting |
| 05:00 - 05:30 | Break and standing reception | |

-

CAMBODIA REDD+ PROGRAMME

# វឌ្ឍនភាពនៃការសម្រេចក្នុងកិច្ចប្រជុំលើកទី២

កិច្ចប្រជុំលើកទី៣ក្រុមការងាររេដ+កម្ពុជា

ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៤

សណ្ឋាគាររ៉ាហ្វល់ឡឺរ៉ូយ៉ាល់

លោក អ៊ុយ កាម៉ាល អនុប្រធានលេខាធិការដ្ឋាន

## វឌ្ឍនភាពនៃការសម្រេចក្នុងកិច្ចប្រជុំលើកទី២

- កែសម្រួលយុទ្ធសាស្រ្តទំនាក់ទំនងរេដ+ (បានអនុវត្ត)
  - ➢ បានកែសម្រួល និងថតចម្លងចែកជូនក្រុមការងារ
- ចែកជូនសេចក្តីសំរេច UNFCCC (បានអនុវត្ត)
  - ➢ សេចក្តីសម្រេចចាប់ពី COP15 ដល់ COP19 បានថតចម្លង និងចែកជូន
- ទស្សនៈកិច្ចសិក្សានៅវៀតណាម (បានអនុវត្ត)
  - ➢ ក្រុមការងាររេដ+ បានចូលរួមទស្សនកិច្ចសិក្សា នៅប្រទេសវៀតណាម ចាប់ពី ថ្ងៃទី ១៣ - ១៧ ខែមករា ឆ្នាំ២០១៤។

CAMBODIA REDD+ NATIONAL PROGRAMME

## វឌ្ឍនភាព នៃការសម្រេចក្នុងកិច្ចប្រជុំលើកទី២

- អញ្ជើញមន្ត្រីបច្ចេកទេសចូលរួមប្រជុំ (បានអនុវត្ត)
  - ➢ បានអញ្ជើញមន្ត្រីបច្ចេកទេសដែលបានចាត់បញ្ជូនពីស្ថាប័នពាក់ព័ន្ធ:
    - ❑ មកចូលរួមប្រជុំពិភាក្សាស្តីពីយន្តការថវិការេដ+
    - ❑ មកចូលរួមកិច្ចប្រជុំលើកទី១ក្រុមបច្ចេកទេស (លើកលែងមន្ត្រីអគ្គនាយកដ្ឋានថាមពល)
- ការចាត់បញ្ជូនមន្ត្រីចូលរួមក្នុងក្រុមបច្ចេកទេសរេដ+ (បានអនុវត្ត)
  - ➢ គ្រប់ស្ថាប័នបានចាត់បញ្ជូនមន្ត្រីមកចូលរួម (នៅសល់ក្រសួងអភិវឌ្ឍន៍ជនបទ)
  - ➢ បានថតចម្លងលិខិតចាត់បញ្ជូនមន្ត្រី និងចែកជូនអ្នកពាក់ព័ន្ធ
  - ➢ បានរៀបចំជាបញ្ជីឈ្មោះក្រុមបច្ចេកទេស និងចែកជូនអ្នកពាក់ព័ន្ធ

CAMBODIA REDD+ NATIONAL PROGRAMME

## សូមអរគុណ

## សំនួរ និងចម្លើយ

CAMBODIA REDD+ NATIONAL PROGRAMME

CAMBODIA REDD+ PROGRAMME

# បច្ចុប្បន្នភាពរេដ+នៅកម្ពុជា

កិច្ចប្រជុំលើកទី៣ក្រុមការងាររេដ+កម្ពុជា

ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៤

សណ្ឋាគារ៉ាហ្វល់ឡឺរ៉ូយ៉ាល់

លោក ឈុន ឌីលុច មន្ត្រីបច្ចេកទេស

# ស្ថានភាពរេដ+កម្ពុជាធៀបនឹងប្រទេសនានា




កម្ពុជាឈានមុខជាងប្រទេសនានានៅអាស៊ីអគ្នេយ៍ លើការងារប្រព័ន្ធធានាសុវត្ថិភាព និងការចែករំលែកផលប្រយោជន៍ ប៉ុន្តែយឺតជាងគេ លើការងារវាស់វែង រាយការណ៍ ផ្ទៀងផ្ទាត់ និងយុទ្ធសាស្ត្ររេដ+ ជាតិ។

CAMBODIA REDD+ NATIONAL PROGRAMME

# មាតិកា

- ស្ថានភាពរេដ+កម្ពុជាធៀបនឹងប្រទេសនានា
- សមាសភាគទី១
- សមាសភាគទី២
- សមាសភាគទី៣
- សមាសភាគទី៤

CAMBODIA REDD+ NATIONAL PROGRAMME

# ទស្សនៈរបស់អ្នកពាក់ព័ន្ធ

Overall Satisfaction




Is REDD+ Readiness on track?




កម្ពុជាត្រូវបង្កើនកម្រិតនៃការពេញចិត្ត និងទស្សនៈដែលថាកម្ពុជាកំពុងដើរលើផ្លូវត្រូវ។

CAMBODIA REDD+ NATIONAL PROGRAMME

## ការយល់ដឹងរបស់អ្នកពាក់ព័ន្ធនៅកម្ពុជាលើការងាររេដ+

ឧទាហរណ៍: ភាគរយនៃអ្នកពាក់ព័ន្ធ ដែលបានដឹងពីចំនួននៃសារពើភ័ណ្ឌព្រៃឈើជាតិ។




Bhutan, Cambodia and Vietnam ប្រសើជាងគេ ដោយមានពិន្ទុខ្ពស់ និងកម្រិតយល់ដឹង ខុសគ្នាតិចតួចរវាង មន្ត្រីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និង អ្នកពាក់ព័ន្ធ

CAMBODIA REDD+ NATIONAL PROGRAMME





## កិច្ចប្រជុំ ក្រុមការងាររេដ+

(២លើក)

CAMBODIA REDD+ NATIONAL PROGRAMME

## សមាសភាគទី១៖ ការគ្រប់គ្រង ទំនាក់ទំនង និងជម្រុញអ្នកពាក់ព័ន្ធចូលរួមអនុវត្ត

គ្រប់សមាសភាគគ្រប់គ្រងរេដ+បានរៀបចំ និងបង្កើត

- ❖ ក្រុមការងាររេដ+បានតែងតាំង និងបានរៀបចំកិច្ចប្រជុំ ចំនួន២លើក
  លើកទី១៖ 11/09/2013 លើកទី២៖ 28/11/2013
- ❖ ក្រុមប្រឹក្សាយោបល់រេដ+បានតែងតាំង និងបានរៀបចំកិច្ចប្រជុំ ចំនួន៤លើក
  ទី១៖ 30/08/2013 ទី២៖ 10/10/2013 ទី3៖ 27/11/2013 ទី4៖ 22/01/2014
- ❖ ក្រុមបច្ចេកទេសរេដ+បានតែងតាំង និងបានរៀបចំកិច្ចប្រជុំចំនួន១លើក
  លើកទី១៖ 20/01/2014

និតិវិធីសម្រាប់គាំទ្រប្រតិបត្តិការឲ្យមានប្រសិទ្ធិភាព កំពុងបង្កើត និងកែសម្រួល

CAMBODIA REDD+ NATIONAL PROGRAMME

## កិច្ចប្រជុំក្រុមប្រឹក្សាយោបល់រេដ+

(៤លើក)



CAMBODIA REDD+ NATIONAL PROGRAMME

## កិច្ចប្រជុំក្រុមបច្ចេកទេសរេដ+
(១លើក)




CAMBODIA REDD+ NATIONAL PROGRAMME

## Website, Twitter, and Concert



CAMBODIA REDD+ NATIONAL PROGRAMME

## សមាសភាគទី១៖ ការគ្រប់គ្រង ទំនាក់ទំនង និងជម្រុញ អ្នកពាក់ព័ន្ធចូលរួមអនុវត្ត(ត)

ទំនាក់ទំនងមានភាពសកម្ម

- Website, Facebook (612 “Likes”), Twitter បានបង្កើត និងកំពុងដំណើរការ
- ឯកសារទំនាក់ទំនងផ្សព្វផ្សាយរួម កំពុងបង្កើត (Video 4 Poster 4)
- វេទិកាប្រគុំតន្ត្រី បានធ្វើនៅថ្ងៃទី១៤ ធ្នូ ២០១៣ ដែលមានអ្នកចូលរួមប្រមាណ ៦000 នាក់ និងការប្រឡងគំនូរ បានធ្វើនៅថ្ងៃទី២៣ វិច្ឆិកា ២០១៣ ដែលមានកុមារចូលរួម ៤២នាក់ ដើម្បីបង្កើនការយល់ពីការប្រែប្រួលអាកាសធាតុ និងតួនាទីព្រៃឈើ និងរេដ+។
- វេទិកាប្រគុំតន្ត្រីនៅថ្នាក់ក្រោមជាតិកំពុងព្រាងរៀបចំ
- តាមរយៈទស្សនកិច្ចសិក្សា បទពិសោធន៍ការងាររបស់កម្ពុជាត្រូវបានចម្លង និងកែសម្រួលសម្រាប់អនុវត្តនៅប្រទេសនានា ឧទាហរណ៍: ប្រទេសមីយ៉ាន់ម៉ា ។

CAMBODIA REDD+ NATIONAL PROGRAMME

## REDD+ Concert



CAMBODIA REDD+ NATIONAL PROGRAMME

# សមាសភាគទី២៖ សមាសធាតុបច្ចេកទេសសម្រាប់យុទ្ធសាស្ត្ររេដ+ជាតិ

## ការសិក្សាជំរើសយន្តការថវិការេដ+

- ការសិក្សាស្តីពីយន្តការថវិកាបានបញ្ចប់
- បានរៀបចំកិច្ចប្រជុំពិភាក្សាលើលទ្ធផលសិក្សា នៅថ្ងៃទី ១០ មករា ២០១៤ ដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធ
- ទីប្រឹក្សាឯករាជ្យបានបង្ហាញជម្រើសស្តីពីយន្តការថវិកាចំនួន៤
- របាយការណ៍ចុងក្រោយនឹងដាក់ជូនកិច្ចប្រជុំក្រុមការងាររេដ+ដើម្បីពិនិត្យ

CAMBODIA REDD+ NATIONAL PROGRAMME





កិច្ចប្រជុំពិភាក្សាលើលទ្ធផលសិក្សា ស្តីពីជំរើសយន្តការថវិការេដ+



CAMBODIA REDD+ NATIONAL PROGRAMME



## ការសិក្សាជំរើសយន្តការថវិការេដ+(ត)

- ជម្រើសទី១៖ A multi-donor REDD+ trust fund គ្រប់គ្រងដោយ គណកម្មាកាថវិកាឯករាជ្យមួយ។
- ជម្រើសទី២៖ រដ្ឋាភិបាលគ្រប់គ្រងថវិការេដ+ជាតិ ដែលបង្កើតឡើងតាមរយៈច្បាប់ថ្មីមួយ។
- ជម្រើសទី៣៖ ថវិការេដ+ ឬ ការផ្តល់ថវិកា ដែលជាផ្នែកមួយ នៅក្នុងថវិកាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ ។
- ជម្រើសទី៤៖ វិសោធនកម្ម ពង្រីកទំហំថវិកា ដែលផ្តល់ឲ្យវិស័យព្រៃឈើ និងតំបន់ការពារធម្មជាតិ ដោយមានចែងច្បាស់លំអិតពីថវិការេដ+ នៅក្នុងច្បាប់។

CAMBODIA REDD+ NATIONAL PROGRAMME



# សមាសភាគទី២៖ សមាសធាតុបច្ចេកទេសសម្រាប់យុទ្ធសាស្ត្រ រេដ+ជាតិ (ត)

## ប្រព័ន្ធធានាសុវត្ថិភាពរេដ+



Version: February 17, 2014

FIRST DRAFT

Preliminary review of safeguards for REDD+ in Cambodia

REDD+ Taskforce Secretariat

- បានព្រាងរៀបចំឯកសារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពរេដ+
- គោលបំណង ផ្តល់ជូនមន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ នូវព័ត៌មានបច្ចេកទេស ដែលត្រូវការសម្រាប់បង្កើតក្របខណ្ឌការងារប្រព័ន្ធធានាសុវត្ថិភាពរេដ+នៅកម្ពុជា។

CAMBODIA REDD+ NATIONAL PROGRAMME



## ជំហ៊ានសំខាន់ៗដើម្បីបង្កើតប្រព័ន្ធធានាសុវត្ថិភាពរេដ+




CAMBODIA REDD+ NATIONAL PROGRAMME

## ជំហ៊ានបន្ទាប់

1. ដាក់ជូនស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ ពិនិត្យឯកសារវិភាគកង្វះចន្លោះ នៃគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានា ថាតើមានអ្វី ដែលនៅខ្វះខាត (កុម្ភៈ មេសា)។
2. សិក្ខាសាលាថ្នាក់ខេត្ត ដើម្បីប្រមូលមតិយោបល់ពីអ្នកពាក់ព័ន្ធ ស្តីពីកំរិត និងប្រភេទនៃគោលការណ៍ប្រព័ន្ធធានាសុវត្ថិភាពរេដ+ ដែលសមស្របបំផុតសម្រាប់កម្ពុជា (មេសា មិថុនា)។
3. សិក្ខាសាលាថ្នាក់ជាតិ ដើម្បីបង្ហាញ ការរួមបញ្ចូលណប្រមូលមតិយោបល់របស់អ្នកពាក់ព័ន្ធស្តីពីគោលការណ៍ និង រៀបចំសំណើ គោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានាសម្រាប់ប្រព័ន្ធធានាសុវត្ថិភាពរេដ+ជាតិកម្ពុជា(កក្កដា សីហា)។
4. កម្ពុជាដាក់សំណើប្រព័ន្ធធានាសុវត្ថិភាពរេដ+ជាតិកម្ពុជា ជូនក្របខណ្ឌអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៅខែកញ្ញា។

CAMBODIA REDD+ NATIONAL PROGRAMME

## មាតិកាសំខាន់ៗ របាយការណ៍ប្រព័ន្ធធានាសុវត្ថិភាពរេដ+

- ហានិភ័យ សង្គម និងបរិស្ថានរបស់រេដ+ និងមូលហេតុដែលនាំឲ្យមានប្រព័ន្ធធានាសុវត្ថិភាពរេដ+(ជំពូក៣)
- គោលការណ៍ណែនាំ ស្តីពីប្រព័ន្ធធានាសុវត្ថិភាពរេដ+របស់ ក្របខណ្ឌអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) (ជំពូក៤)
- គោលការណ៍ប្រព័ន្ធធានាសុវត្ថិភាពរេដ+ សំខាន់ៗដែលបានស្នើឡើងនៅលើពិភពលោក (UN-REDD, FCPF, CCBA & Care International) (ជំពូក៥)
- កង្វះចន្លោះនៃគោលការណ៍ប្រព័ន្ធធានាសុវត្ថិភាពរេដ+ពិភពលោក និងគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានា ដែលមាននៅកម្ពុជា (ជំពូក៦)
- មេរៀននិងបទពិសោធន៍ដែលទទួលបានពី ឧត្តរមានជ័យ និងសីម៉ា កម្ពុជា (ជំពូក៧)
- មេរៀននិងបទពិសោធន៍ដែលទទួលបានពី វៀតណាម និងឥណ្ឌូនេស៊ី(ជំពូក៨)

CAMBODIA REDD+ NATIONAL PROGRAMME



## សមាសភាគទី៣៖ ការកសាងសមត្ថភាពថ្នាក់ក្រោមជាតិ និងការអនុវត្តគម្រោងគំរូ

- ❖ ការធ្វើសុពលភាព: គម្រោងរេដ+សីម៉ា (ខេត្តមណ្ឌលគិរី) កំពុងដំណើរការ ដែលរំពឹងថានឹងបញ្ចប់នៅដំណាច់ឆ្នាំ២០១៤។
- ❖ ទស្សនកិច្ចសិក្សានៅកម្ពុជា
  - ម៉ាឡេស៊ីុ: ០៤ ដល់ ០៦ ខែធ្នូ មាន០៩ នាក់ (គម្រោងរេដ+សីម៉ា)
  - មីយ៉ាន់ម៉ា: ០៩ ដល់ ១៣ ខែមករា មាន០៥ នាក់(គម្រោងរេដ+សីម៉ា)
  - ថៃឡង់: ១៥ ដល់ ១៨ ខែមករា មាន២១ នាក់(គម្រោងរេដ+ឧត្តរមានជ័យ)

ទស្សនកិច្ចសិក្សាមានគោលបំណងផ្លាស់ប្តូរបទពិសោធន៍ ស្តីពីការត្រៀមលក្ខណៈរេដ+ របស់កម្ពុជា ដើម្បីធានាឲ្យមានការចូលរួមពេញលេញ និងមានប្រសិទ្ធិភាព ពីគ្រប់ភាគីពាក់ព័ន្ធ។



## Thailand Country Team






CAMBODIA REDD+ NATIONAL PROGRAMME

## Myanmar Country Team






CAMBODIA REDD+ NATIONAL PROGRAMME

## សមាសភាគទី៤៖ ប្រព័ន្ធត្រួតពិនិត្យថ្នាក់ជាតិ

- ❖ ស្ថានភាពការងារសារពើភ័ណ្ឌព្រៃឈើជាតិ: សំណើស្តីពីសារពើភ័ណ្ឌព្រៃឈើជាតិ បានធ្វើបទបង្ហាញនៅថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១៣



- <u>សំណាកគំរូ</u>
- ✓ តំបន់ខ្ពង់រាប: 6 km x 6 km
- ✓ តំបន់ដីសើម: 4 km x 4 km
- ✓ ព្រៃកោងកាង: 3 km x 3 km

CAMBODIA REDD+ NATIONAL PROGRAMME

## សមាសភាគទី៤៖ ប្រព័ន្ធត្រួតពិនិត្យថ្នាក់ជាតិ (ត)



- ជំហ៊ានបន្ទ: សៀវភៅណែនាំស្តីពីសារពើភ័ណ្ឌព្រៃឈើជាតិ កំពុងរៀបចំបង្កើត និងផ្តល់ការបណ្តុះបណ្តាលជូនអ្នកពាក់ព័ន្ធ។
- លទ្ធផល នឹងបង្ហាញជូនក្រុមការងាររេដ+ ដើម្បីពិភាក្សានៅក្នុងកិច្ចប្រជុំខែមីនា

CAMBODIA REDD+ NATIONAL PROGRAMME

## សូមអរគុណ

## សំនួរ និងចម្លើយ

Website: www.cambodia-redd.org

CAMBODIA REDD+ NATIONAL PROGRAMME

## សមាសភាគទី៤៖ ប្រព័ន្ធត្រួតពិនិត្យថ្នាក់ជាតិ (ត)

❖ ស្ថានភាពការងារ ប្រព័ន្ធត្រួតពិនិត្យព្រៃឈើតាម Web Platform

- បានប្រមូល ទិន្នន័យសារពើភ័ណ្ឌព្រៃឈើដែលមានស្រាប់
- បានធ្វើសារពើភ័ណ្ឌ ម្ចាស់ទិន្នន័យ រូបភាពផ្កាយរណប (satellite data holdings)
- បានបង្កើតផែនទីសូចនាករណ៍ (index maps)
- ជំហ៊ានបន្ទ: NFI Module នឹងសាកល្បងជំហ៊ានទី១ ដែលនឹងយកមកពិភាក្សាក្នុងកិច្ចប្រជុំក្រុមបច្ចេកទេស និងបង្ហាញជូនក្រុមការងាររេដ+ផងដែរ។

CAMBODIA REDD+ NATIONAL PROGRAMME

CAMBODIA REDD+ PROGRAMME

# Update on REDD+ in Cambodia

Third meeting of the REDD+ Taskforce
Raffle Le Royal Hotel, 21 February, 2014
Mr. Chhun Delux, Technical Staff

## Where Does Cambodia Stand (compared with other countries)?




Cambodia is more advanced than SE Asia (and all-Asia) averages for Safeguards and BDS, but lags behind for MRV and development of National REDD+ Strategy

CAMBODIA REDD+ NATIONAL PROGRAMME

## Content

- Where Does Cambodia Stand
- Component 1
- Component 2
- Component 3
- Component 4

CAMBODIA REDD+ NATIONAL PROGRAMME

## Stakeholder perceptions







Need to increase level of satisfaction and perceptions that Cambodia is on track

CAMBODIA REDD+ NATIONAL PROGRAMME

## But in some areas Cambodian stakeholders have good knowledge

Example: What percentage of stakeholders knew the correct number of NFIs?




**Bhutan, Cambodia and Viet Nam are best: high scores and little difference between government officials and non-governmental stakeholders**

CAMBODIA REDD+ NATIONAL PROGRAMME



Taskforce Meeting



CAMBODIA REDD+ NATIONAL PROGRAMME

## Component 1: Management, Communications and Stakeholder Engagement

All components of REDD+ management are now in place:

- REDD+ Taskforce, first meeting September, 2013
- REDD+ Consultation Group, first meeting September, 2013
- REDD+ Technical Teams, first meetings January, 2014

Procedures for efficient operation of all components are currently being developed and refined

CAMBODIA REDD+ NATIONAL PROGRAMME

Consultation Group Meeting



CAMBODIA REDD+ NATIONAL PROGRAMME

## Technical Team Meeting




CAMBODIA REDD+ NATIONAL PROGRAMME






## Website, Twitter, and Concert



CAMBODIA REDD+ NATIONAL PROGRAMME

## Component 1: Management, Communications and Stakeholder Engagement

<u>Very active communications</u>:

- Website, Facebook (612 “Likes”), Twitter
- Development of a common set of communications materials (RTS has been developing 4 videos and 4 posters)
- REDD+ drawing competition and concert in December. The event is to raise awareness about climate change, the role of forests, and REDD+ among the general public and others. 44 children in 2 age categories in drawing; over 6,000 attended the concert.
- Additional events, including sub-national concerts, being planned
- Many aspects of Cambodia’s work are now being adopted by other countries through lessons learnt in study tours; e.g., Myanmar adopting a common set of communications

CAMBODIA REDD+ NATIONAL PROGRAMME



## REDD+ Concert

CAMBODIA REDD+ NATIONAL PROGRAMME

## Component 2: Technical Elements of National REDD+ Strategy (REDD+ Fund)

Options for REDD+ Fund Status: Consultation meeting 10 January 2014 with 46 participants from relevant ministries and development partners.

The consultant highlighted four options (see next slide).

Next step: A synthesis report will be shared with the Taskforce with a view to discuss next steps.

CAMBODIA REDD+ NATIONAL PROGRAMME





Technical Meeting on REDD+ Fund Mechanism

CAMBODIA REDD+ NATIONAL PROGRAMME

## Component 2: Technical Elements of National REDD+ Strategy (REDD+ Fund)

**Option 1:** A multi-donor REDD+ trust fund, administered by an independent trustee; (**recommended by the consultant**)

**Option 2:** A government-administered National REDD+ Fund established through a new Law;

**Option 3:** A REDD+ sub-fund or funding 'window' within a new National Climate Change Fund;

**Option 4:** Amendment and expansion of the Fund provisions within the Law on Forestry or Law on Protected Areas to explicitly enable REDD+ funding and incorporate necessary details.

CAMBODIA REDD+ NATIONAL PROGRAMME

## Component 2: Technical Elements of National REDD+ Strategy


FIRST DRAFT

Preliminary review of safeguards for REDD+ in Cambodia

**Safeguards Status**: a first draft technical paper developed.

**Objective**: to provide the RGC and other stakeholders with technical information required for developing a national REDD+ safeguard framework

CAMBODIA REDD+ NATIONAL PROGRAMME

## Main steps for development of a national safeguards system






## Next steps

1. Request to relevant governments to review the gap analysis to see if any Policies, laws and Regulations (PLRs) are missed under the review: **February-April**
2. **3 regional workshops** to receive feedback from stakeholders on types and levels of safeguard principles that would be appropriate for Cambodia: **April-June**
3. **A national workshop** to present a consolidated view of stakeholders on safeguard principles and to make an initial proposal for a national REDD+ safeguard PLR: **July/August**
4. Cambodia to submit its national safeguard experience to UNFCCC **by September**



## Key contents of the report

- Social and environmental risks of REDD+ and key rationales for safeguards (chapter 3)
- UNFCCC guidelines for safeguards (chapter 4)
- Key safeguard principles proposed at the global level (UN-REDD, FCPF, CCBA & Care International) (chapter 5)
- Gaps between global safeguard principles and existing policies, laws and regulations (PLRs) in Cambodia (chapter 6)
- Lessons learned from Oddar Meanchey and Seima, Cambodia (chapter 7)
- Lessons learned from Vietnam and Indonesia (chapter 8)





## Component 3: Sub-national capacity building and demonstration projects

Keo Seima (Mondulkiri) validation process is in the process and hope to finish in the latest of this year.

Study Tours from Malaysia, Myanmar and Thailand visited Seima and Oddar Meanchey:

- Malaysia (4-6 December, 7 visitors visited Seima )
- Myanmar (9-13 January, 5 visitors visited Seima )
- Thailand (15-18 January, 21 visitors visited Oddar Meanchey)

Study Tour is to exchange lessons and experiences on approaches of Cambodia in implementing REDD+ Readiness and to ensure the full and effective participation of all relevant stakeholders in REDD+ readiness.

CAMBODIA REDD+ NATIONAL PROGRAMME

## Thailand Country Team






CAMBODIA REDD+ NATIONAL PROGRAMME

## Myanmar Country Team






CAMBODIA REDD+ NATIONAL PROGRAMME

## Component 4: National Monitoring Systems

National Forest Inventory Status: NFI design proposal presented 13 December.



Potential field sample sites

Uplands: 6 km x 6 km
Wetlands: 4 km x 4 km

2nd phase
Mangroves: 3 km x 3 km

CAMBODIA REDD+ NATIONAL PROGRAMME

## Component 4: National Monitoring Systems



- Next Step: NFI manual being developed and training provided.
- Results will be shared with the Taskforce to discuss next steps at the meeting in March.

CAMBODIA REDD+ NATIONAL PROGRAMME

## Thanks You

## Questions & Answers

